រាល់របាយការណ៍នៃកិច្ចប្រជុំរបស់ **ក.ជ.វ.ប.ន.** ត្រូវផ្ញើជូនសមាជិកនៃ **ក.ជ.វ.ប.ន.** យ៉ាងយូរត្រឹម១៥ (ដប់ប្រាំ)ថ្ងៃ ក្រោយពីកិច្ចប្រជុំ។ ការបញ្ជូនរបាយការណ៍នេះ អាចធ្វើតាមប្រព័ន្ធអនឡាញ (Online) ឬតាមមធ្យោបាយផ្សេងទៀត ដែលអាចទៅដល់សមាជិកនៃ **ក.ជ.វ.ប.ន.**។

សេចក្តីសម្រេចឬរបាយការណ៍របស់ **ក.ជ.វ.ប.ន.** ត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរ និងរក្សាទុកនៅលេខាធិការដ្ឋាន **ក.ជ.វ.ប.ន.** ដោយមានចុះហត្ថលេខារបស់ប្រធាន ឬអនុប្រធាន តាមការប្រគល់សិទ្ធិពីប្រធាន **ក.ជ.វ.ប.ន.**។

**ប្រការ៥.-**

លេខាធិការដ្ឋានមានសិទ្ធិទទួលការអនុញ្ញាតពីប្រធាន **ក.ជ.វ.ប.ន.** ក្នុងការទទួល និងចាត់ចែងប្រើប្រាស់នូវមូលនិធិឧបត្ថម្ភធនជាមូលធនអំណោយ ឬជំនួយ អច្ច័យទាន និងកម្រៃសេវាកម្មសាធារណៈ ឬភាគទាន ដែលបានមកពីប្រភពស្របច្បាប់ផ្សេងៗទៀតតាមនីតិវិធីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានសម្រាប់ដំណើរការការងាររបស់ខ្លួន។


ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ឧទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

**ប្រការ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល និងលេខាធិការដ្ឋាន **ក.ជ.វ.ប.ន.** គ្រប់អង្គភាពក្រោមឱវាទក្រសួងដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១រោច ខែ ជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០២១

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា**
**និងនវានុវត្តន៍**
**និងជាប្រធានក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា**
**និងនវានុវត្តន៍**

*កិត្តិសេដ្ឋាបណ្ឌិត* **ចម ប្រសិទ្ធ**

**កន្លែងទទួល៖**
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៧
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

**Annex 5: Royal Decree on the appointment of STI advisory board**

# ព្រះរាជក្រឹត្យ

នស/រកត/១២២០/ ១៣៧០២

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០២០/១០៧៣ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីការគ្រប់គ្រង និងការបើកផ្ដល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១** : តែងតាំង និងផ្ដល់ឋានៈដល់ឥស្សរជន និងបញ្ញវន្ត ២៣រូប ឱ្យបំពេញមុខងារជាប្រធាន អនុប្រធាន និងសមាជិក គណៈប្រឹក្សាយោបល់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ របស់ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ :

| | |
|---|---|
| ១-ឯកឧត្តម **ឆែម គាតរិទ្ធី** | ប្រធាន បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២-ឯកឧត្តម **ចែម ផល្លា** | អនុប្រធាន ឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣-ឯកឧត្តម **ឡឹម តារា** | សមាជិក ឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៤-ឯកឧត្តម **ធន់ វឌ្ឍនា** | សមាជិក ឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៥-ឯកឧត្តម **ទី ឡាយមិថុនា** | សមាជិក ឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៦-ឯកឧត្តម **ឡេង គីរស្មី** | សមាជិក ឋានៈស្មើ រដ្ឋលេខាធិការ |
| ៧-ឯកឧត្តម **យៀង សុធី** | សមាជិក ឋានៈស្មើ រដ្ឋលេខាធិការ |
| ៨-ឯកឧត្តម **ឈឹម សារ៉ាត** | សមាជិក ឋានៈស្មើ អនុរដ្ឋលេខាធិការ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

១

៩- ឯកឧត្តម **ទិន ឡៃវជ្ជ** សមាជិក ឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
១០-ឯកឧត្តម **ផន គន្ធា** សមាជិក ឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
១១-ឯកឧត្តម **ហុក លីដា** សមាជិក ឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
១២-ឯកឧត្តម **ឈុន តូរី** សមាជិក ឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
១៣-ឯកឧត្តម **ស្រ៊ីវ ថារិទ្ធ** សមាជិក ឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
១៤-ឯកឧត្តម **ហ៊ីង ធុត្ថា** សមាជិក ឋានៈស្មើ អនុរដ្ឋលេខាធិការ
១៥-លោកជំទាវ **អ៊ុច ច័ន្ទតាវ៉ានី** សមាជិក ឋានៈស្មើ អនុរដ្ឋលេខាធិការ
១៦-ឯកឧត្តម **ហេង ម៉េងហូ** សមាជិក ឋានៈស្មើ អនុរដ្ឋលេខាធិការ
១៧-ឯកឧត្តម **ឌុទ្ធី មុនីរ័ត្ន** សមាជិក ឋានៈស្មើ អនុរដ្ឋលេខាធិការ
១៨- ឯកឧត្តម **ជួន ច័ន្ទណារ៉ែណា** សមាជិក ឋានៈស្មើ អគ្គនាយក
១៩-ឯកឧត្តម **ប៊ិត សុចិត្ត** សមាជិក ឋានៈស្មើ អគ្គនាយក
២០-លោកជំទាវ **ជា រដ្ឋា** សមាជិក ឋានៈស្មើ អគ្គនាយក
២១-ឯកឧត្តម **ទីរៈ ខ្លូតដា** សមាជិក ឋានៈស្មើ អគ្គនាយក
២២-ឯកឧត្តម **ឈឹម ឈល់** សមាជិក ឋានៈស្មើ អគ្គនាយក
២៣-ឯកឧត្តម **យឹម ប្រសិទ្ធីឫទ្ធិ** សមាជិក ឋានៈស្មើ អគ្គនាយក។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

ចរ.ស.២០១៤.១៣៤៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០២០*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

២

## Annex 6: Decision on the roles and responsibilities of STI advisory board

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation
លេខ: ១១៩ MISTI / ២០២១

**សេចក្តីសម្រេច**
**ស្តីពី**
**ការកំណត់តួនាទីនិងភារកិច្ចរបស់គណៈប្រឹក្សាយោបល់**
**វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២០/១០៧៣ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២០/១៣០៦ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការតែងតាំង និងផ្តល់ឋានៈដល់ឥស្សរជន និងបញ្ញវន្ត នៃគណៈប្រឹក្សាយោបល់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងតាមសំណូមពរការងារចាំបាច់

**សម្រេច**

**ប្រការ១._**

ត្រូវបានកំណត់អំពីតួនាទី និងភារកិច្ចរបស់គណៈប្រឹក្សាយោបល់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (**គ.ប.វ.ប.ន.**) ដើម្បីជួយការងារ ឬផ្តល់យោបល់ជូនក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (**ក.ជ.វ.ប.ន.**) ស្របទៅតាមបទប្បញ្ញត្តិដែលមានចែងក្នុងប្រការខាងក្រោម។

១


ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

**ប្រការ២.-**

សមាជិករបស់ **គ.ប.វ.ប.ន.** ត្រូវមានលក្ខណសម្បត្តិ និងបទពិសោធន៍ដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរពីកំណើត
- ពុំធ្លាប់ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋដែលពាក់ព័ន្ធនឹងទំនុកចិត្ត និងសមត្ថភាពប្រកបវិជ្ជាជីវៈ
- មានបទពិសោធន៍ធ្លាប់បម្រើការងារយ៉ាងតិច ៥(ប្រាំ)ឆ្នាំ
- មានសមត្ថភាពជំនាញនៅក្នុងវិស័យគ្រប់គ្រង សេដ្ឋកិច្ច អប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៣.-**

**គ.ប.វ.ប.ន.** មានតួនាទីជាសេនាធិការក្នុងការប្រឹក្សា និងពិគ្រោះយោបល់ និងផ្តល់មតិជូនដល់ **ក.ជ.វ.ប.ន.** និងមានភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវ ស្វែងរក កំណត់ឬសគល់ ប្រមើលមើលហានិភ័យ និងផលបច្ច័យនៃបញ្ហាចម្បងៗដែលពាក់ព័ន្ធនឹងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា សង្គមជាតិ និងធ្វើរបាយការណ៍អំពីការសិក្សាស្រាវជ្រាវជូនដល់ **ក.ជ.វ.ប.ន.**
- សិក្សាស្រាវជ្រាវ ផ្តួចផ្តើមគំនិត និងផ្តល់យោបល់លើការធ្វើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ព្រមទាំងជំរុញអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព ផែនការថវិកា និងកម្មវិធីអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ផ្តល់គំនិតយោបល់ក្នុងការកសាងក្របខណ្ឌវាយតម្លៃ ការរីកចម្រើននៃការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ផ្តល់គំនិតយោបល់លើកម្មវិធីអប់រំ ការកំណត់គោលការណ៍ និងផែនការអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- លើកជាយោបល់ឬទស្សនៈផ្សេងៗ ដើម្បីចាប់យកកាលានុវត្តភាពដែលបានមកពីបដិវត្តន៍ឧស្សាហកម្ម និងត្រៀមទុកជាមុនក្នុងការបង្កើត ឬចាប់យកបច្ចេកវិទ្យាថ្មីៗក្នុងស្រុក និងក្រៅប្រទេស
- កំណត់តម្រូវការជាអាទិភាពនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលស្នើឡើងដោយក្រសួង ស្ថាប័ន សមាគម អង្គការជាតិ អន្តរជាតិ និងអង្គភាពឯកជនដែលមានការពាក់ព័ន្ធ
- ចូលរួមក្នុងការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ចូលរួមកៀរគរជំនួយ ការគាំទ្រ និងជំរុញឱ្យមានធនធានហិរញ្ញវត្ថុ បច្ចេកទេស និងធនធានមនុស្សដែលជាតម្រូវការអាទិភាពជាតិនៃស្ថាប័ន ឬអង្គភាពដែលពាក់ព័ន្ធនឹងការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍
- ផ្តល់គំនិត យោបល់ និងចូលរួមអភិវឌ្ឍន៍ប្រព័ន្ធអេកូនវានុវត្តន៍ជាតិជាអាទិ៍ កម្មសិទ្ធិបញ្ញា ការអប់រំ ការស្រាវជ្រាវ សហប្រតិបត្តិការរវាងស្ថាប័នរដ្ឋ និងឯកជន សម្របសម្រួល សហគ្រិនភាព ស្ថាបនូបនីយកម្ម និងពាណិជ្ជកម្មជាដើម
- ធ្វើការស្រាវជ្រាវ បោះពុម្ព និងលើកតម្កើងការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលជាស្នាដៃផ្ដើមមកពីគ្រប់មជ្ឈដ្ឋាន



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

- ចូលរួមផ្តល់យោបល់លើការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងគម្រោងកម្មវិធីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ហើយធ្វើរបាយការណ៍ជូន **ក.ជ.វ.ប.ន.**
- ចូលរួមលើការងារបណ្តុះបណ្តាល និងជំរុញការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- គោរពក្រមសីលធម៌វិជ្ជាជីវៈ គោរពវិន័យ និងបទបញ្ជាផ្ទៃក្នុងរបស់ **គ.ប.វ.ប.ន.**
- បំពេញភារកិច្ចផ្សេងៗទៀតតាមការណែនាំរបស់ប្រធាន **ក.ជ.វ.ប.ន.**។

**ប្រការ៤.-**

សមាជិកភាពនៃ **គ.ប.វ.ប.ន.** មានសុពលភាពអចិន្ត្រៃយ៍។ សមាជិកភាពនៃ **គ.ប.វ.ប.ន.** នឹងអាចត្រូវបានបញ្ចប់បាន ក្នុងករណីដែលសមាជិករូបនោះបាត់បង់ភាពស្របច្បាប់របស់ខ្លួនជាតំណាងក្រសួង ស្ថាប័ន អង្គភាពដែលមានការពាក់ព័ន្ធនៅក្នុង **គ.ប.វ.ប.ន.** ឬដោយសារករណីទទួលមរណភាព ការសុំលាឈប់ជាលាយលក្ខណ៍អក្សរ ការបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬក្នុងករណីសមាជិករូបនោះត្រូវបានផ្តន្ទាទោសពីបទល្មើសមជ្ឈិម ឬឧក្រិដ្ឋណាមួយ។

ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីក្នុងក្របខណ្ឌនៃការអនុវត្តមុខងារជាសមាជិក **គ.ប.វ.ប.ន.** ជាបន្ទុករបស់ **ក.ជ.វ.ប.ន.** លើកលែងតែករណីដែលសមាជិកនោះបានប្រព្រឹត្តកំហុសដោយចេតនា ឬដោយការធ្វេសប្រហែសធ្ងន់ធ្ងរ។

ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ជាការទទួលខុសត្រូវរបស់សមាជិកម្នាក់ៗចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។

**ប្រការ៥.-**

ដំណើរការនៃកិច្ចប្រជុំរបស់ **គ.ប.វ.ប.ន.** ត្រូវប្រព្រឹត្តទៅយ៉ាងតិចមួយលើកក្នុងមួយត្រីមាស(បីខែ) តាមការអញ្ជើញរបស់ប្រធាន **គ.ប.វ.ប.ន.**។ ក្នុងករណីចាំបាច់ ប្រធានអាចកោះប្រជុំជាវិសាមញ្ញបាន។

ក្នុងពេលដែលប្រធានអវត្តមានដោយជាប់បំពេញភារកិច្ចផ្សេង ឬមានករណីចាំបាច់ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធានដើម្បីដឹកនាំការប្រជុំតាមការប្រគល់សិទ្ធិពីប្រធាន។ ក្នុងករណីអនុប្រធានមានធុរៈចាំបាច់មិនអាចដឹកនាំការប្រជុំជំនួសប្រធានបាន ប្រធានអាចប្រគល់ភារកិច្ចជូនទៅសមាជិកណាម្នាក់ ដឹកនាំការប្រជុំតាមការប្រគល់សិទ្ធិពីប្រធាន។

របៀបវារៈនៃកិច្ចប្រជុំ ពេលវេលា និងទីកន្លែងនៃដំណើរការកិច្ចប្រជុំ ត្រូវបានកំណត់ដោយប្រធាន **គ.ប.វ.ប.ន.** និងត្រូវបានជម្រាបផ្សព្វផ្សាយជូនព័ត៌មានជាមុនដល់សមាជិក **គ.ប.វ.ប.ន.**។

ការប្រជុំអាចប្រព្រឹត្តទៅបាន លុះត្រាតែសមាជិកចូលរួមមានចំនួនលើសពី ៥០%(ហាសិប)ភាគរយឡើងទៅនៃសមាជិក **គ.ប.វ.ប.ន.**។

**ប្រការ៦.-**

អគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើរតួនាទីជាសេនាធិការជួយសម្របសម្រួលដំណើរការការងាររបស់ **គ.ប.វ.ប.ន.**។ ក្នុងការបំពេញតួនាទីនេះ អគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍មានសិទ្ធិប្រើប្រាស់មន្ត្រីរបស់ខ្លួនដើម្បីជួយការងារ **គ.ប.វ.ប.ន.** តាមការចាំបាច់។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

អគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចេញកំណត់ហេតុឬរបាយការណ៍ក្នុងរយៈពេល១០(ដប់)ថ្ងៃយ៉ាងយូរ បន្ទាប់ពីកិច្ចប្រជុំរបស់ **គ.ប.វ.ប.ន.**។ រាល់កំណត់ហេតុឬរបាយការណ៍នៃកិច្ចប្រជុំរបស់ **គ.ប.វ.ប.ន.** ត្រូវផ្ញើជូនសមាជិកនៃ **គ.ប.វ.ប.ន.** យ៉ាងយូរត្រឹម១៥(ដប់ប្រាំ)ថ្ងៃក្រោយពីកិច្ចប្រជុំ។ ការបញ្ជូនរបាយការណ៍នេះអាចធ្វើឡើងតាមប្រព័ន្ធអនឡាញ (Online) ឬតាមមធ្យោបាយផ្សេងទៀត ដែលអាចទៅដល់សមាជិកនៃ **គ.ប.វ.ប.ន.**។

កំណត់ហេតុកិច្ចប្រជុំរបស់ **គ.ប.វ.ប.ន.** ត្រូវបានរៀបចំឡើងដោយលេខាធិការនៃកិច្ចប្រជុំ ដែលទទួលបានការចាត់តាំងពីប្រធានអង្គប្រជុំ។ កំណត់ហេតុនៃកិច្ចប្រជុំត្រូវដាក់ជូនប្រធានអង្គប្រជុំចុះហត្ថលេខាដោយមានហត្ថលេខាអមរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៧.-**

**គ.ប.វ.ប.ន.** មានសិទ្ធិទទួលការអនុញ្ញាតពី **ក.ជ.វ.ប.ន.** ក្នុងការទទួល និងចាត់ចែងប្រើប្រាស់នូវមូលនិធិឧបត្ថម្ភធនជាមូលធនអំណោយ ជំនួយ អច្ច័យទាន និងកម្រៃសេវាកម្មសាធារណៈ ឬភាគទានដែលបានមកពីប្រភពស្របច្បាប់ផ្សេងៗទៀត អនុលោមតាមការសម្រេចរបស់ **ក.ជ.វ.ប.ន.** សម្រាប់ដំណើរការការងាររបស់ខ្លួន ស្របទៅតាមនីតិវិធីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល និង**គ.ប.វ.ប.ន.** គ្រប់ស្ថាប័នអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៣រោច ខែ ជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ២០២១

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា**

**និងនវានុវត្តន៍**

**និងជាប្រធានក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា**

**និងនវានុវត្តន៍**

***កិត្តិសេដ្ឋាបណ្ឌិត* ចម ប្រសិទ្ធ**

**កន្លែងទទួល៖**

- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ដូចប្រការ៩
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: mist.smcabinet@gmail.com

**Annex 7: Government approved the R&D Management Sub-decree and the National STI Day**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ :** ១៧៤៨.សរណ

ថ្ងៃសុក្រ ៩កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ជម្រាបជូន**

**ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងជាប្រធានក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**កម្មវត្ថុ** ៖ ករណីរបាយការណ៍សង្ខេបអំពីលទ្ធផលនៃកិច្ចប្រជុំលើកទី២ ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**យោង** ៖- លិខិតលេខ001 MISTI/២០២២ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២២ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២២។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតជ្រាបថា រាជរដ្ឋាភិបាលឯកភាពនូវការងារសំខាន់បន្ទាន់ចំនួនពីរ ដូចខាងក្រោម៖

១- រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងការស្រាវជ្រាវនិងអភិវឌ្ឍន៍។

២- បង្កើតឱ្យមានទិវាជាតិ វ.ប.ន. សម្រាប់ប្រទេសកម្ពុជា នាថ្ងៃទី២៦ ខែមីនា ដែលជាថ្ងៃបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ខូយ យុនហ៊ីរ**

**ចម្លងជូន៖**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ឯកសារ កាលប្បវត្តិ

## Annex 8: Government decision on the NCSTI’s request after the 3rd NCSTI meeting

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ៩៣ សជណ.ប្រ

ថ្ងៃ ចន្ទ ២កើត ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ ២០២៣

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**
**ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**កម្មវត្ថុ៖** ករណីរបាយការណ៍សង្ខេបអំពីលទ្ធផលនៃកិច្ចប្រជុំលើកទី៣ ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**យោង ៖** - លិខិតលេខ០៤៥ MISTI/២០២២ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតជ្រាបថា រាជរដ្ឋាភិបាលគាំទ្រលើគំនិតផ្តួចផ្តើម និងសំណើរបស់ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍( ក.ជ.វ.ប.ន.) នូវចំណុចដូចខាងក្រោម៖

-រៀបចំបង្កើតមជ្ឈមណ្ឌលជាតិផ្ទេរបច្ចេកវិទ្យា
-រៀបចំបង្កើតសួនវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
-គាំទ្រទាំងស្មារតីនិងហិរញ្ញវត្ថុដើម្បីរៀបចំទិវាជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជារៀងរាល់ឆ្នាំ នៅថ្ងៃទី២៦ ខែមីនា
-ប្រគល់សិទ្ធិជូនប្រធាន ក.ជ.វ.ប.ន. សម្រេចលើបទបញ្ហាផ្ទៃក្នុងរបស់ ក.ជ.វ.ប.ន.។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ខូយ ឃុនហ៊ួរ**

**ចម្លងជូន៖**
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
-ឯកសារ កាលប្បវត្តិ

## Annex 9: Decision on the appointment of the sub-committees for Cambodia National COSTI

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation
លេខ: ១៤៨ MISTI / ២០២១

**សេចក្តីសម្រេច**
**ស្តីពី**
**ការចាត់តាំងសមាសភាពអនុគណៈកម្មាធិការជាតិទាំង៩ នៃគណៈកម្មាធិការជាតិ សម្រាប់កិច្ចសហប្រតិបត្តិការអាស៊ាន ផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងជារដ្ឋមន្ត្រីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍សម្រាប់កម្ពុជា ក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៨/០១២ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៨ ស្តីពីការអនុម័តយល់ព្រមលើធម្មនុញ្ញនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០០ ស្តីពីការបង្កើតគណៈកម្មាធិការជាតិទាំង៦ សម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកជំនាញ (Functional Cooperation)
- យោងសេចក្តីសម្រេចលេខ ០៩៥ MISTI/២០២១ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ ស្តីពីការចាត់តាំងសមាសភាពនៃគណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ ០០៦ MISTI/២០២១ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ ៧៣៥ សវ/អស៊/កបទ.សអ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

១

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

- យោងលិខិតចាត់តាំងសមាសភាពឱ្យចូលរួមក្នុងអនុគណៈកម្មាធិការជាតិទាំង៩ នៃគណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ាន ផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ របស់បណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១.-**

ត្រូវបានចាត់តាំងសមាសភាព នៃអនុគណៈកម្មាធិការជាតិស្តីពី ជីវបច្ចេកវិទ្យា (Biotechnology) ដែលមានសមាសភាព៖

| | | |
|---|---|---|
| ១. លោកបណ្ឌិត **សេង វ៉ាង** | ប្រធាននាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២. លោកវេជ្ជបណ្ឌិត **ចៅ តារាក័ក្រ** | ប្រធានមន្ទីរពិសោធន៍ នៃវិទ្យាស្ថានជាតិសុខភាពសាធារណៈ នៃក្រសួងសុខាភិបាល | សមាជិក |
| ៣. លោក **យក់ សុទ្ធារិទ្ធ** | អនុប្រធាននាយកដ្ឋានជីវចម្រុះ នៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព នៃក្រសួងបរិស្ថាន | សមាជិក |
| ៤. លោក **សុខ វង្ហា** | អនុប្រធាននាយកដ្ឋានកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៥. លោកស្រីបណ្ឌិត **សួង ម៉ាលីណា** | អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្ត នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | សមាជិក |
| ៦. លោកស្រី **ចេង គីមហ៊ាង** | ប្រធានការិយាល័យ នៃនាយកដ្ឋានផ្ទេរបច្ចេកវិទ្យា នៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិកាអចិន្ត្រៃយ៍ |
| ៧. លោកបណ្ឌិត **យឿន សេរីរ័ទ្ធ** | អ្នកស្រាវជ្រាវ និងគ្រូបង្រៀនកម្រិតឧត្តមសិក្សា នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | សមាជិក |
| ៨. លោកបណ្ឌិត **ហ៊ុយ ហង់សាក់** | អ្នកស្រាវជ្រាវ និងគ្រូបង្រៀនកម្រិតឧត្តមសិក្សា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៩. កញ្ញា **ហ៊ិន គីមឈីន** | មន្ត្រីមន្ទីរពិសោធន៍ជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |

**ប្រការ២.-**

ត្រូវបានចាត់តាំងសមាសភាពនៃអនុគណៈកម្មាធិការជាតិស្តីពី វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាហារ (Food Science and Technology) ដែលមានសមាសភាព៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ផាន អូន** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ នៃក្រសួងពាណិជ្ជកម្ម | ប្រធាន |



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីមែល: mistr.smcabinet@gmail.com

| | | |
|---|---|---|
| ២. លោកស្រីបណ្ឌិត **យក់ សុគន្ធស្រីរតន៍** | ប្រធានមន្ទីរពិសោធន៍ជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ៣. លោកបណ្ឌិត **សោ វង្ខា** | ព្រឹទ្ធបុរសសាលាក្រោយបរិញ្ញាបត្រ នៃសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ | សមាជិក |
| ៤. លោកស្រី **ហួ បុប្ផា** | អនុប្រធាននាយកដ្ឋានកសិ-ឧស្សាហកម្ម នៃអគ្គនាយកដ្ឋានកសិ-ឧស្សាហកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥. លោកស្រីបណ្ឌិត **តាន់ រស្មី** | អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្ត នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | សមាជិក |
| ៦. លោកស្រីបណ្ឌិត **ផាត ច័ន្ទវរលក្ខណ៍** | ប្រធានផ្នែកស្រាវជ្រាវបច្ចេកវិទ្យាអាហារ និងអាហារូបត្ថម្ភ នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | សមាជិក |
| ៧. លោកស្រីបណ្ឌិត **ប៉េង ចាន់ថុល** | ប្រធានផ្នែកស្រាវជ្រាវទឹក និងបរិស្ថាន នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | សមាជិក |
| ៨. លោក **ស៊ឹម វិចិត្រ** | ប្រធានការិយាល័យ នៃនាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់ នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន នៃក្រសួងបរិស្ថាន | សមាជិក |
| ៩. កញ្ញា **តាំង ចាន់រស្មី** | ប្រធានការិយាល័យ នៃនាយកដ្ឋានសហប្រតិបត្តិការវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិកអចិន្ត្រៃយ៍ |
| ១០. លោក **ខៀវ សុធី** | អនុប្រធានការិយាល័យសុវត្ថិភាពចំណីអាហារ នៃនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង នៃក្រសួងសុខាភិបាល | សមាជិក |
| ១១. លោស្រីបណ្ឌិត **ឡុង សូលីដា** | អ្នកស្រាវជ្រាវ និងគ្រូបង្រៀនកម្រិតឧត្តមសិក្សា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១២. លោក **ជា សំអាត** | មន្ត្រីកម្មសិក្សា នៃនាយកដ្ឋានឧស្សាហកម្ម បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៃអគ្គនាយកដ្ឋាន បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |

**ប្រការ៣.-**

ត្រូវបានចាត់តាំងសមាសភាពនៃអនុគណៈកម្មាធិការជាតិស្តីពី វិទ្យាសាស្ត្រសមុទ្រ និងបច្ចេកវិទ្យា (Marine Science and Technology) ដែលមានសមាសភាព៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ថៃ ចន្ថា** | ប្រធាននាយកដ្ឋានអភិរក្សសមុទ្រ និងតំបន់ឆ្នេរ នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន | ប្រធាន |
| ២. លោក **ស៊ុយ សេរីវឌ្ឍន៍** | ប្រធានវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍សមុទ្រ នៃរដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៣. លោកបណ្ឌិត **អ៊ឹង ប៉ោស្រ៊ី** | ប្រធាននាយកដ្ឋានជំរុញអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

| | | |
|---|---|---|
| ៤. លោក **សៀក សុផាត** | ព្រឹទ្ធបុរសរង និងប្រធានកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រ<br>ប្រែប្រួលអាកាសធាតុ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៥. លោក **ហ៊ិន សុទ្ធី** | អនុប្រធាននាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ<br>នៃក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៦. លោក **សូអ៊ីម មណីជោតិ** | អនុប្រធាននាយកដ្ឋានឧតុនិយម<br>នៃក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៧. លោក **បួយ រតនា** | អនុប្រធានរដ្ឋបាលជលផល<br>នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨. កញ្ញា **ឈុំ មួយនី** | ប្រធានការិយាល័យ នៃនាយកដ្ឋានតាមដាន ត្រួតពិនិត្យ<br>និងវាយតម្លៃការអនុវត្តគោលនយោបាយ នៃអគ្គនាយកដ្ឋាន<br>វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម<br>វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិកអចិន្ត្រៃយ៍ |
| ៩. លោកបណ្ឌិត **ដួង រដ្ឋា** | អ្នកស្រាវជ្រាវ និងគ្រូបង្រៀនកម្រិតឧត្តមសិក្សា<br>នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | សមាជិក |
| ១០. លោកបណ្ឌិត **អៀង យីអៀម** | អ្នកស្រាវជ្រាវ និងគ្រូបង្រៀនកម្រិតឧត្តមសិក្សា<br>នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | សមាជិក |
| ១១. លោកស្រីបណ្ឌិត **ឡុង សូលីដា** | អ្នកស្រាវជ្រាវ និងគ្រូបង្រៀនកម្រិតឧត្តមសិក្សា<br>នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១២. លោក **ឈួន សុកម៉ានិត** | អ្នកស្រាវជ្រាវ និងគ្រូបង្រៀនកម្រិតឧត្តមសិក្សា<br>នៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា នៃក្រសួង<br>ប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |

**ប្រការ៤.-**

ត្រូវបានចាត់តាំងសមាសភាពនៃអនុគណៈកម្មាធិការជាតិស្តីពី វិទ្យាសាស្ត្ររូបធាតុ និងបច្ចេកវិទ្យា (Materials Science and Technology) ដែលមានសមាសភាព៖

| | | |
|---|---|---|
| ១. លោកបណ្ឌិត **យស់ ផានី** | ប្រធានផ្នែកស្រាវជ្រាវវិទ្យាសាស្ត្ររូបធាតុ និងគ្រឿងបង្គុំ<br>នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ប្រធាន |
| ២. ឯកឧត្តមបណ្ឌិត **ស៊្រើរ ថារិទ្ធ** | អ្នកស្រាវជ្រាវ និងគ្រូបង្រៀនកម្រិតឧត្តមសិក្សា<br>នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៣. លោក **គួន ប៊ុនធឿន** | ប្រធាននាយកដ្ឋានបច្ចេកទេសសាធារណការ និងដឹកជញ្ជូន<br>នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៤. លោកបណ្ឌិត **តូ តារា** | ប្រធាននាយកដ្ឋានបណ្តុះបណ្តាលវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង<br>នវានុវត្តន៍ នៃវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ៥. លោក **ទូ សុធូ** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ<br>និងទំនាក់ទំនងអន្តរជាតិ នៃអគ្គនាយកដ្ឋានរដ្ឋបាល<br>នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

| | | |
|---|---|---|
| ៦. លោក **អាំង ហៃផេង** | អនុប្រធានមន្ទីរពិសោធន៍ នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន<br>នៃក្រសួងបរិស្ថាន | សមាជិក |
| ៧. លោក **លឹម យ៉ុងហួត** | អនុប្រធាននាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ<br>ការអនុវត្តគោលនយោបាយ នៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ<br>បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម<br>វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិកអចិន្ត្រៃយ៍ |
| ៨. លោកស្រី **អ៊ា ម៉ូនីកា** | ប្រធានការិយាល័យសហប្រតិបត្តិការស្រាវជ្រាវ និងអភិវឌ្ឍន៍<br>នៃនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍ នៃវិទ្យាស្ថានជាតិ<br>វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម<br>វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ៩. លោក **លាង សុជារ៉ា** | អ្នកស្រាវជ្រាវ និងគ្រូបង្រៀនកម្រិតឧត្តមសិក្សា<br>នៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា<br>នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |

**ប្រការ៥.-**

ត្រូវបានចាត់តាំងសមាសភាពនៃអនុគណៈកម្មាធិការជាតិស្តីពី ឧតុនិយម និងភូគព្ភសាស្ត្ររូបវន្ត (Meteorology and Geophysics) ដែលមានសមាសភាព៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ពេជ្រ វាសនា** | អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ប្រធាន |
| ២. លោក **ឌឹម វណ្ណជេត** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការវិស័យវិទ្យាសាស្ត្រ<br>បច្ចេកវិទ្យា និងនវានុវត្តន៍ នៃអគ្គនាយកដ្ឋាន វិទ្យាសាស្ត្រ<br>បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ<br>បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិកអចិន្ត្រៃយ៍ |
| ៣. លោក **កាន់ វិបុល** | អនុប្រធាននាយកដ្ឋានសេវាកម្ម និងព័ត៌មានភូមិសាស្ត្រ<br>នៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន<br>នៃក្រសួងបរិស្ថាន | សមាជិក |
| ៤. លោក **អំ ភិរម្យ** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងដីកសិកម្ម នៃអគ្គនាយកដ្ឋាន<br>កសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥. លោកស្រី **គឹម ឡាង** | អនុប្រធាននាយកដ្ឋានរដ្ឋាភិបាលអេឡិចត្រូនិក<br>នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន<br>នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៦. លោកបណ្ឌិត **អេង ចាន់ឌឿន** | ព្រឹទ្ធបុរសរង នៃមហាវិទ្យាល័យរ៉ែ និងភូគព្ភសាស្ត្រ<br>នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | សមាជិក |
| ៧. លោកបណ្ឌិត **ឈិន រតនា** | អ្នកស្រាវជ្រាវ និងគ្រូបង្រៀនកម្រិតឧត្តមសិក្សា<br>នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | សមាជិក |
| ៨. លោកបណ្ឌិត **ក្រែត កក្កដា** | អ្នកស្រាវជ្រាវ និងគ្រូបង្រៀនកម្រិតឧត្តមសិក្សា<br>នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | សមាជិក |



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីមែល: misti.smcabinet@gmail.com

៩. លោកបណ្ឌិត **ឈិញ នីដា** អ្នកស្រាវជ្រាវ និងគ្រូបង្រៀនកម្រិតឧត្តមសិក្សា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សមាជិក

១០. លោក **សែ ប៊ុនលេង** អ្នកស្រាវជ្រាវ និងគ្រូបង្រៀនកម្រិតឧត្តមសិក្សា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សមាជិក

**ប្រការ៦.-**

ត្រូវបានចាត់តាំងសមាសភាពនៃអនុគណៈកម្មាធិការជាតិស្តីពី បច្ចេកវិទ្យាព័ត៌មាន និងមីក្រូអេឡិចត្រូនិក (Microelectronics and Information Technology) ដែលមានសមាសភាព៖

១. ឯកឧត្តម **សំ សិទ្ធិសេរី** អនុប្រធានវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រធាន

២. លោក **ឈន វិបុល** ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ នៃក្រសួងព័ត៌មាន សមាជិក

៣. លោក **ប៊ី ណារិន** អនុប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៤. លោកបណ្ឌិត **សៀវ សុខលី** អនុប្រធាននាយកដ្ឋានគោលនយោបាយ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃអគ្គនាយកដ្ឋាន វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សមាជិក

៥. លោក **បុត្រ សុភ័ក្ត្រ** អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃវិទ្យាស្ថានជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សមាជិក

៦. លោក **ង៉ែត ស៊ីណា** ប្រធានការិយាល័យ នៃនាយកដ្ឋានអប់រំបរិស្ថាន នៃអគ្គនាយកដ្ឋាន ចំណេះដឹង និងព័ត៌មានបរិស្ថាន នៃក្រសួងបរិស្ថាន សមាជិក

៧. លោក **ដាន់ តាំងអូន** ប្រធានការិយាល័យ នៃមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៨. លោក **សោម សួគ៌** ប្រធានការិយាល័យ នៃនាយកដ្ឋានគ្រប់គ្រងព័ត៌មាន វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃអគ្គនាយកដ្ឋាន វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សមាជិកអចិន្ត្រៃយ៍

៩. លោកបណ្ឌិត **វ៉ាលី ដូណា** អ្នកស្រាវជ្រាវ និងគ្រូបង្រៀនកម្រិតឧត្តមសិក្សា នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សមាជិក

១០. លោកបណ្ឌិត **គីម ប៊ុនធឿន** អ្នកស្រាវជ្រាវ និងគ្រូបង្រៀនកម្រិតឧត្តមសិក្សា នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សមាជិក



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

**ប្រការ៧.-**

ត្រូវបានចាត់តាំងសមាសភាពនៃអនុគណៈកម្មាធិការជាតិស្តីពី កម្មវិធី និងបច្ចេកវិទ្យាលំហ (Space Technology and Applications) ដែលមានសមាសភាព៖

| | | |
|---|---|---|
| ១. លោក **អ៊ឹង សុភា** | ប្រធាននាយកដ្ឋានគោលនយោបាយផ្កាយរណប នៃអគ្គនាយកដ្ឋានទូរគមនាគមន៍ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ប្រធាន |
| ២. ឯកឧត្តម **សាន ពុទ្ធារី** | ទីប្រឹក្សា និងប្រធាននាយកដ្ឋានសោតទស្សន៍ នៃក្រសួងព័ត៌មាន | សមាជិក |
| ៣. លោក **សុខ សុភាព** | ប្រធានការិយាល័យ នៃមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៤. លោក **ចិន សុវណ្ណ** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងព័ត៌មាន វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃអគ្គនាយកដ្ឋាន វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិកអចិន្ត្រៃយ៍ |
| ៥. លោក **ហ៊ិន សុទ្ធី** | អនុប្រធាននាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ នៃក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៦. លោក **សូអ៊ីម មណីជោតិ** | អនុប្រធាននាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៧. លោកបណ្ឌិត **ស្រង់ សារ៉ុត** | ប្រធានផ្នែកស្រាវជ្រាវមេកាត្រូនិក និងបច្ចេកវិទ្យាព័ត៌មាន នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | សមាជិក |
| ៨. លោក **តាំង គីមម៉េង** | មន្ត្រីបច្ចេកទេស នាយកដ្ឋានរង្វាន់ និងលើកទឹកចិត្ត នៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន នៃក្រសួងបរិស្ថាន | សមាជិក |

**ប្រការ៨.-**

ត្រូវបានចាត់តាំងសមាសភាពនៃអនុគណៈកម្មាធិការជាតិស្តីពី ការស្រាវជ្រាវនិរន្តរថាមពល (Sustainable Energy Research) ដែលមានសមាសភាព៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ស៊ុយ ឌីម៉ង់** | រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | ប្រធាន |
| ២. លោកបណ្ឌិត **អោ ច័ន្ទម៉ូលី** | ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្ត នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | សមាជិក |
| ៣. លោក **ណុប សុខខៃ** | អនុប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព នៃក្រសួងបរិស្ថាន | សមាជិក |
| ៤. លោក **ចាន់ វិសាល** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិកអចិន្ត្រៃយ៍ |

| | | |
|---|---|---|
| ៥. លោក **សូ វិទូ** | អនុប្រធាននាយកដ្ឋានផលិតកម្មសត្វ នៃអគ្គនាយកដ្ឋាន<br>សុខភាពសត្វ និងផលិតកម្មសត្វ នៃក្រសួងកសិកម្ម<br>រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៦. លោកបណ្ឌិត **ចាន់ សារិទ្ធ** | ប្រធានផ្នែកស្រាវជ្រាវបច្ចេកវិទ្យាថាមពល និងគ្រប់គ្រង<br>នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | សមាជិក |
| ៧. លោក **ជា សុជាតិ** | អ្នកស្រាវជ្រាវ និងគ្រូបង្រៀនកម្រិតឧត្តមសិក្សា<br>នៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា<br>នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |

**ប្រការ៩._**

ត្រូវបានចាត់តាំងសមាសភាពនៃអនុគណៈកម្មាធិការជាតិស្តីពី អភិវឌ្ឍន៍ធនធាន និងហេដ្ឋារចនាសម្ព័ន្ធវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ( S&T Infrastructure and Resources Development ) ដែលមានសមាសភាព៖

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត **អឿង ចន្ថា** | នាយករង នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ប្រធាន |
| ២. ឯកឧត្តម **ថង សាម៉ុន** | ទីប្រឹក្សា និងអគ្គនាយករង នៃអគ្គនាយកដ្ឋានអប់រំ<br>បណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួង<br>ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៣. ឯកឧត្តម **ឡៅ បញ្ញវ័ន្ត** | ទីប្រឹក្សា និងប្រធាននាយកដ្ឋានគ្រប់គ្រងរោងពុម្ព<br>នៃក្រសួងព័ត៌មាន | សមាជិក |
| ៤. លោក **គៀង ហាក់** | ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានសុរិយោដី<br>នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ នៃក្រសួង<br>រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៥. លោក **ប៊ុន ឆាយ** | ប្រធាននាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍ នៃវិទ្យាស្ថាន<br>សេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦. លោក **គង់ ឌីវ៉ង់** | អនុប្រធាននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧. លោក **ហ៊ាប សុខហួច** | អនុប្រធាននាយកដ្ឋានផ្ទេរបច្ចេកវិទ្យា នៃអគ្គនាយកដ្ឋាន<br>វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម<br>វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិកអចិន្ត្រៃយ៍ |
| ៨. លោក **យក់ សុទ្ធារិទ្ធ** | អនុប្រធាននាយកដ្ឋានជីវចម្រុះ នៃអគ្គលេខាធិការដ្ឋាន<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព នៃក្រសួងបរិស្ថាន | សមាជិក |
| ៩. កញ្ញា **សុង លក្ខិណា** | អនុប្រធានការិយាល័យ  នៃនាយកដ្ឋានវិទ្យាសាស្ត្រ<br>និងបច្ចេកវិទ្យា នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិ<br>អភិវឌ្ឍន៍ដោយចីរភាព នៃក្រសួងបរិស្ថាន | សមាជិក |
| ១០. លោកបណ្ឌិត **រ៉េត ធារម្យ** | អ្នកស្រាវជ្រាវ និងគ្រូបង្រៀនកម្រិតឧត្តមសិក្សា<br>នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១១. លោក **ជិន វណ្ណៈ** | អ្នកស្រាវជ្រាវ និងគ្រូបង្រៀនកម្រិតឧត្តមសិក្សា<br>នៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា<br>នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

**ប្រការ១០.-**

តួនាទី និងភារកិច្ចរបស់អនុគណៈកម្មាធិការជាតិទាំង៩ នៃគណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ាន ផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍សម្រាប់កម្ពុជា ក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)។

**ប្រការ១១.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល គ្រប់អង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៤កើត ខែឧត្តិអាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០២១

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**និងជារដ្ឋមន្ត្រីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍សម្រាប់កម្ពុជា**

**ក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)**

*កិត្តិសេដ្ឋាបណ្ឌិត* **ចម ប្រសិទ្ធ**

**កន្លែងទទួល៖**

- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- លេខាធិការដ្ឋានជាតិអាស៊ាន
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ១១
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

**Annex 10: Decision on appointment committee for the Cambodia National COSTI**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

Ministry of Industry, Science, Technology & Innovation

លេខ: ០៩៤ MISTI / ២០២១

# សេចក្ដីសម្រេច

## ស្ដីពី

## ការចាត់តាំងសមាសភាពនៃគណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ាន ផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងជារដ្ឋមន្ត្រីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍សម្រាប់កម្ពុជា ក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៨/០១២ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៨ ស្ដីពីការអនុម័តយល់ព្រមលើធម្មនុញ្ញនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០០ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិទាំង៦ សម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកជំនាញ (Functional Cooperation)
- យោងលិខិតលេខ ០០៦ MISTI/២០២១ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ ៧៣៥ សវ/អស៊/កបទ.សអ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

# សម្រេច

**ប្រការ១.-**

ត្រូវបានចាត់តាំងសមាសភាពគណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ASEAN-Committee on Science, Technology & Innovation, ASEAN-COSTI) ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត ឆែម គាតវិទ្ធី | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ប្រធាន |
| ២. ឯកឧត្តមបណ្ឌិត សាន វឌ្ឍនា | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
